**ធម្មទេសនារបស់លោកអភិបាលអូលីវីយេ**
**អភិបូជាបុណ្យហែរស្លឹកនៅជ្រៃធំ**
**ថ្ងៃទី០៩ មេសា ២០១៧**

អត្ថបទទី១៖ អស ៥០,៤-៧
អត្ថបទទី២៖ ភីល ២,៦-១១
ដំណឹងល្អ៖ មថ ២៦,១៤ដល់២៧,៦៦

បងប្អូនជាទីស្រឡាញ់!

យើងបានធ្វើដំណើរជាមួយព្រះយេស៊ូអស់៤០ថ្ងៃកន្លងមកហើយ ពីថ្ងៃដែលព្រះយេស៊ូទៅវាលរហោស្ថាន រហូតដល់ព្រះយេស៊ូបានធ្វើដំណើរទៅទីក្រុងយេរូសាឡឹម។ ក្នុង៤០ថ្ងៃនេះ យើងខិតខំជាប់ជាមួយព្រះយេស៊ូរបៀបថ្មី។ ក្នុងអត្ថបទពេលយើងហែរស្លឹក យើងឃើញថាមហាជនសប្បាយជាមួយព្រះយេស៊ូ កំពុងទទួលស្វាគមន៍ព្រះយេស៊ូដែលជាព្រះរាជ្យវង្សព្រះបាទដាវីឌ។ គេកំពុងនឹកឃើញអ្វីៗទាំងអស់ ដែលព្រះយេស៊ូបានធ្វើសម្រាប់ពួកគេ ព្រះយេស៊ូណែនាំឲ្យគេមានម្ហូបអាហារបរិភោគ ព្រះយេស៊ូបានព្យាបាលអ្នកជំងឺនានា ឲ្យអ្នកពិការជាធម្មតាវិញ អ្នកក្រីក្រមានសេចក្តីសង្ឃឹម។ ស្រ្តីសាម៉ារីនឹកឃើញជីវិតថ្មីដែលគាត់បានទទួល លោកឡាសានឹកឃើញពីជីវិតរស់ឡើងវិញពីសេចក្តីស្លាប់ មនុស្សជាច្រើននាក់ដែលបានទទួលបទពិសោធន៍ផ្ទាល់ពីព្រះយេស៊ូ និងគេច្រៀងកោតសរសើរដោយទទួលស្គាល់ថា ព្រះយេស៊ូជាព្រះមហាក្សត្ររបស់ពួកគេ។ ក្រុមគ្រីស្តទូតសប្បាយចិត្ត នៅពេលគេឃើញមានមហាជនមកគាំទ្រព្រះយេស៊ូ ក្រុមគ្រីស្តទូតបានរស់នៅជាមួយព្រះយេស៊ូ ដោយបានទទួលការអប់រំ ណែនាំឲ្យគេស្គាល់ព្រះហឫទ័យរបស់ព្រះបិតា។ នៅពេលក្រុមគ្រីស្តទូតឃើញមហាជនមកគាំទ្រព្រះយេស៊ូ ក្រុមគ្រីស្តទូតមានអំណរសប្បាយពេញខ្លួនដែរ។ ប៉ុន្តែព្រះមហាក្សត្ររបស់គេ គ្មានបល្ល័ង្ក គ្មានរទេះមាស គឺទ្រង់មានតែសត្វលាដើម្បីធ្វើដំណើរទៅដល់ទីក្រុងយេរូសាឡឹម។ ព្រះមហាក្សត្រនេះគ្មានអង្គរក្ស គ្មានទាហានដើម្បីការពារ គឺមានតែប្រជាជនដែលបានកាន់ស្លឹកឈើ។ ព្រះមហាក្សត្រនេះគ្មានរដ្ឋមន្រ្តី មានតែក្រុមគ្រីស្តទូតដែលបានតស៊ូជាមួយទ្រង់។ យើងត្រូវការនឹកឃើញដល់កន្លែងដែលព្រះមហាក្សត្រដែលបានទទួលការកោតសរសើរពីមហាជន គឺព្រះមហាក្សត្រនេះបានប្រសូតនៅក្នុងក្រោលគោនៃភូមិបេថ្លេហឹម។

ហេតុនេះហើយ បើយើងនឹកឃើញពីសម័យដើមព្រះយេស៊ូបានចាប់កំណើតជាមនុស្ស នៅកន្លែងក្រខ្សត់បំផុត។ ព្រះយេស៊ូបានរស់នៅ ជាមួយមនុស្សយើងក្នុងភូមិណា

សារតែក្នុងរបៀបសាមញ្ញធម្មតាបំផុត រហូតដល់ព្រះយេស៊ូទៅទីក្រុងយេរូសាឡឹម ទោះបីគេកោតសរសើរព្រះអង្គជាព្រះមហាក្សត្រ ប៉ុន្តែព្រះអង្គនៅតែបន្តរបៀបក្រីក្រដូចពេលព្រះយេស៊ូចាប់កំណើតជាមនុស្ស ដើម្បីធ្វើដំណើរជាមួយយើងរហូតដល់ចុងក្រោយ។ ពេលដល់ទីក្រុងយេរូសាឡឹមហើយ ព្រះយេស៊ូបានជួបជុំគ្នាជាមួយក្រុមគ្រីស្តទូត ដោយសារដល់ពេលវេលាគោរពបុណ្យចម្លងតាមសាសនាយូដា។ ប៉ុន្តែយប់នោះគេមិនគោរពបុណ្យចម្លងដូចរាល់ឆ្នាំតាំងពីជំនាន់លោកម៉ូសេ នៅយប់នោះព្រះយេស៊ូបានយកនំប៉័ងហើយមានព្រះបន្ទូលថា **"នេះជាព្រះកាយរបស់ខ្ញុំដែលបានបូជាសម្រាប់អ្នករាល់គ្នា"** ព្រះយេស៊ូបានយកស្រាទំពាំងបាយជូរនិងមានព្រះបន្ទូលថា **"នេះជាលោហិតរបស់ខ្ញុំដែលបង្ហូរដើម្បីរំដោះបាបអ្នករាល់គ្នា"**។ ព្រះកាយនិងព្រះលោហិត មិនមែនជាព្រះកាយនិងព្រះលោហិតធម្មតាដើម្បីណែនាំឲ្យមនុស្សលោកទទួលការសង្គ្រោះ។ នៅពេលនោះក្រុមគ្រីស្តទូតគេស្តាប់មិនយល់អ្វីដែលកើតឡើង ព្រះយេស៊ូកំពុងមានព្រះបន្ទូលអំពីអ្វី។ ព្រះយេស៊ូដឹងគេមិនយល់ ប៉ុន្តែព្រះយេស៊ូបន្តធ្វើដំណើរទៅមុខ ដោយបានទៅសួនច្បារកេតសេម៉ានីនៅពេលនោះមានក្រុមគ្រីស្តទូតបីនាក់ ដែលបាននិយាយថាយើងនៅជាមួយព្រះអង្គជានិច្ច ក៏ប៉ុន្តែគេដេកលក់។

ពីព្រះយេស៊ូទៅសួនច្បារកេតសេម៉ានី រហូតព្រះយេស៊ូសោយទិវង្គតលើឈើឆ្កាង យើងចូលនៅក្នុងការរងទុក្ខលំបាករបស់ព្រះយេស៊ូ ណែនាំឲ្យយើងនឹកឃើញដល់ជីវិតរបស់យើងផ្ទាល់។ ក្នុងការរងទុក្ខលំបាករបស់ព្រះយេស៊ូមានលោកយូដា មានលោកសិលា មានលោកប៉ុនពីឡាត់ មានលោកយូដាស់ មានទាហាន មានបូជាចារ្យ មានមហាជន ដែលណែនាំឲ្យយើងនឹកឃើញដល់ជីវិតរបស់យើង និងដល់ទំនាក់ទំនងដែលយើងមានជាមួយព្រះយេស៊ូប្រចាំថ្ងៃ។ យូដាស់អ៊ីស្ការីយ៉ូត បានធ្វើដំណើរជាមួយព្រះយេស៊ូដូចក្រុមគ្រីស្តទូតទាំងអស់ ជាអ្នកដែលព្រះជាម្ចាស់បានជ្រើសរើស ដែលព្រះជាម្ចាស់បានតែតាំង ដែលព្រះជាម្ចាស់បានអប់រំ តែគាត់នៅក្បត់ព្រះយេស៊ូ។ គាត់បានទទួលការណែនាំពីមហាបូជាចារ្យឲ្យចាប់ព្រះយេស៊ូដោយថើបព្រះយេស៊ូ នៅពេលនោះព្រះយេស៊ូមានព្រះបន្ទូលថា **"សម្លាញ់អើយ"**។ ទោះបីលោកយូដាស់ក្បត់ព្រះយេស៊ូ តែព្រះអង្គនៅតែបន្តហៅគាត់សម្លាញ់។ នៅពេលនេះជាឱកាសមួយ ដើម្បីគិតអំពីជីវិតរបស់យើងផ្ទាល់ ជួនកាលយើងបានក្បត់ព្រះយេស៊ូ យើងបានថើបព្រះយេស៊ូដោយមានគំនិតផ្សេង។ ដែលខាងក្នុងចិត្តរបស់

យើង មានអ្វីដែលណែនាំឲ្យយើងប្រឆាំងនឹងព្រះយេស៊ូ ឲ្យយើងដើរឆ្ងាយពីព្រះយេស៊ូ ដូចលោកយ៉ូដាស់ដែរ។

លោកសិលាជាគ្រីស្តទូតរឹងមាំ ដែលបានធ្វើដំណើរជាមួយព្រះយេស៊ូយ៉ាងជិតស្និតបំផុត ជាអ្នកដែលបានប្រកាសមុនគេបង្អស់ថា ពិតមែនលោកជាព្រះបុត្រារបស់ព្រះបិតា។ លោកសិលាដែលធ្លាប់និយាយថា កន្លែងណាដែលព្រះអង្គទៅខ្ញុំទៅដែរ ប៉ុន្តែនៅពេលគេចាប់ព្រះយេស៊ូ ហើយមានគេសួរគាត់លោកធ្លាប់នៅជាមួយយេស៊ូឬ? គាត់បានបដិសេធបីម្តង **"ខ្ញុំមិនស្គាល់លោកនេះទេ"** ពេលនោះមាន់រងាវ ព្រះយេស៊ូទតមើលលោកសិលាដោយចិត្តស្រឡាញ់។ លោកសិលាយំសោគស្តាយ ដោយសារគាត់បានក្បត់មិត្តសម្លាញ់ជិតស្និតបំផុតរបស់លោក ជាព្រះបុត្រារបស់ព្រះជាម្ចាស់។ ជួនកាលយើងដូចលោកសិលាដែរ យើងចង់មានជំនឿរឹងមាំដើរតាមព្រះយេស៊ូ ដោយយើងបានចូលក្នុងក្រុមផ្សេងៗក្រោយមកយើងចោលទាំងអស់។

ទាហានដែលស្អប់ ដែលមើលងាយ ដែលវាយព្រះយេស៊ូ ពេលគេឃើញព្រះយេស៊ូសោយទិវង្គត គេចាប់ផ្តើមភ្ញាក់ថា អ្នកនេះពិតមែនមិនធម្មតាទេ។ យើងមើលមហាជនដែលបានស្រែកថា ឆ្កាងទៅៗ បាណាបាស់ៗ ណែនាំឲ្យយើងយល់ថាមហាជនដែលបានធ្វើដំណើរជាមួយព្រះយេស៊ូ ដោយទទួលស្វាគមន៍ព្រះយេស៊ូចូលទីក្រុងយេរូសាឡឹម គឺមហាជននេះដដែលដែលបានស្រែកអស់ពីកម្លាំងកាយចិត្ត ឆ្កាងទៅៗ។ ក្នុងចំណោមមហាជននោះ មានលោកសាខេ មានស្ត្រីសាម៉ារី មានមនុស្សជាច្រើននាក់ទៀតដែលបានទទួលជីវិតថ្មីពីព្រះយេស៊ូ ប៉ុន្តែគេឆ្លើយដូចអ្នកឯទៀតៗឲ្យឆ្កាងព្រះយេស៊ូដែរ។

ទុក្ខលំបាករបស់ព្រះយេស៊ូ ថ្ងៃនេះទៅជារឿងយើងផ្ទាល់ យើងដឹងថានៅក្បែរឈើឆ្កាងរបស់ព្រះយេស៊ូនៅសល់តែពីរនាក់ គឺលោកយ៉ូហានសាវ័កជាទីស្រឡាញ់របស់ព្រះអង្គ និងនាងម៉ារីមាតារបស់ព្រះអង្គ។ នៅក្នុងជីវិតរបស់យើង ជួនកាលយើងដូចយ៉ូដាស់ យើងដូចសិលា ដូចមហាជន ដូចទាហាន ហើយជួនកាលយើងដូចព្រះនាងម៉ារីនឹងសន្តយ៉ូហាននៅក្បែរព្រះយេស៊ូ។ ប៉ុន្តែ យើងដឹងថាយើងដូចអ្នកណាក៏ដោយព្រះយេស៊ូគង់នៅជាមួយយើងជានិច្ច និងមិនដែលចោលយើងសោះ។ នៅពេលនេះយើងសម្លឹងមើលព្រះយេស៊ូនៅលើឈើឆ្កាង ព្រះយេស៊ូបានយកនំប៉័ងនេះជារូបកាយ បានយកស្រានេះជាលោហិត ពិត

មែនរូបកាយ និងលោហិតរបស់ព្រះគ្រីស្តទៅជាជីវិតនៅលើឈើឆ្កាង។ ព្រះយេស៊ូបានបូជាជីវិតមិនមែនតែនំនិងស្រាដែលព្រះអង្គបានបង្ហាញ គឺខ្លួននិងជីវិតរបស់ព្រះយេស៊ូផ្ទាល់។ ពីព្រះយេស៊ូចាប់កំណើតជាមនុស្ស រហូតដល់ព្រះយេស៊ូសោយទិវង្គត ណែនាំឲ្យយើងចូលនៅក្នុងជំនឿយ៉ាងរឹងមាំ។ ព្រះយេស៊ូបានចាប់កំណើតជាមនុស្ស ដើម្បីឲ្យមនុស្សទាំងអស់ទទួលជីវិតអស់កាលជានិច្ច។

ចុងក្រោយឲ្យយើងបន្តចូលនៅក្នុងជីវិតរបស់ព្រះយេស៊ូ ក្នុងអាទិត្យពិសិដ្ឋនេះជាឱកាសមួយឲ្យយើងចូលយ៉ាងជ្រៅ ក្នុងអ្វីដែលព្រះយេស៊ូបានប្រទានឲ្យយើង។ ព្រះយេស៊ូបានណែនាំឲ្យយើងធ្វើជាអ្នកបម្រើ ព្រះយេស៊ូបានណែនាំឲ្យយើងលះបង់ចោលដើម្បីទទួលជីវិតអស់កាលជានិច្ច។ ឲ្យយើងបន្តអធិដ្ឋានសម្រាប់គ្នាទៅវិញទៅមក ឲ្យព្រះសហគមន៍របស់យើង ទៅជាព្រះសហគមន៍របស់ព្រះគ្រីស្តដែលចេះស្រឡាញ់គ្នា ដែលចេះបង្ហាញជីវិតដែលព្រះយេស៊ូបានប្រទានឲ្យយើង។ អាម៉ែន។